# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ៩៤ អយក.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងលើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យនៅវិទ្យាស្ថានជាតិអប់រំ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញាឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បកចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៤ ស្តីពីការប្រែក្លាយមហាវិទ្យាល័យគរុកោសល្យទៅជាវិទ្យាស្ថានជាតិអប់រំ
- បានឃើញប្រកាសលេខ១៧៨ អយក.ប្រក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកំណត់តួនាទីបេសកកម្ម ភារកិច្ច និងរចនាសម្ព័ន្ធ របស់វិទ្យាស្ថានជាតិអប់រំ
- បានឃើញប្រកាសលេខ១៤៦៦ អយក.ប្រក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ ស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សា នៅវិទ្យាស្ថានជាតិអប់រំ
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ១ .-**

បង្កើតគណៈកម្មការគ្រប់គ្រងគម្រោងលើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ ដែលមានទីតាំងនៅក្នុងវិទ្យាស្ថានជាតិអប់រំសម្រាប់បណ្តុះបណ្តាលគ្រូថ្នាក់បរិញ្ញាបត្រ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ ដើម្បីអនុវត្តកិច្ចព្រមព្រៀងរវាងក្រសួងអប់រំ យុវជន និងកីឡា និង អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា(ខេប) ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ក្នុងការជំរុញការសិក្សាស្រាវជ្រាវ និងប្រឹក្សាគរុកោសល្យនៅតាមសាលារៀនជំនាន់ថ្មី និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូសម្រាប់ពង្រឹងគុណភាពអប់រំនៅកម្ពុជា។

**ប្រការ២.-**

គណៈកម្មការគ្រប់គ្រងគម្រោងលើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ មានសមាសភាព តួនាទី ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

**ក. គណៈកម្មការគ្រប់គ្រងគម្រោងលើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ**

| | | | | | |
|---|---|---|---|---|---|
| ១. | ឯឧ.ប.សកាចារ្យ | **ណាត** | **ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ប្រធាន |
| ២. | ឯកឧត្តម | **ម៉ក់** | **ខយ** | អគ្គនាយក នៃអគ្គ.នាយកដ្ឋានឧត្តមសិក្សា | អនុប្រធាន |
| ៣. | ឯកឧត្តម | **ទូន** | **មាស** | អគ្គនាយក នៃអគ្គ. រដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. | ឯកឧត្តមបណ្ឌិត | **សៀង** | **សុវណ្ណា** | នាយកវិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៥. | ល.ជំទាវបណ្ឌិត | **ឃួន** | **វិចិត្រា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៦. | ឯកឧត្តម | **ទេព** | **តិយ្យោរិទ្ធ** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ | សមាជិក |
| ៧. | លោកបណ្ឌិត | **ហេង** | **គ្រេង** | ប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ៨. | លោក | **ឃីត** | **ផ្រេដិនប៊ឺក** | ទីប្រឹក្សាអន្តរជាតិ នៃអង្គការ ខេប | សមាជិក |
| ៩. | លោក | **សៅ** | **វណ្ណា** | នាយកប្រតិបត្តិនៃអង្គការ ខេប | សមាជិក |
| ១០. | លោកបណ្ឌិត | **ច័ន្ទ** | **រ័ត្ន** | ប្រធានមជ្ឈ.ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី | លេខាធិការ |

**ខ.** គណៈកម្មការនេះមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- ដឹកនាំ ចាត់ចែងការងារទូទៅ និងត្រួតពិនិត្យ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងបច្ចេកទេស
- ពិនិត្យ និងសម្រេចលើសំណើគម្រោងរៀបចំអនុវត្តផែនការសកម្មភាព ការងារគម្រោងថវិកា ការងារបច្ចេកទេស
- គ្រប់គ្រងអនុគណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាល និងអនុគណៈកម្មការរដ្ឋបាល និង ហិរញ្ញវត្ថុ
- រៀបចំផែនការសកម្មភាពសម្រាប់ការបណ្តុះបណ្តាលទទួលបានជោគជ័យ ដោយមានការចូលរួមគាំទ្រពីបណ្តាស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គភាព និងអ្នកពាក់ព័ន្ធក្នុងនិងក្រៅប្រទេស
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍រាល់ការបំពេញការងារ ភារកិច្ចនិងការទទួលខុសត្រូវរបស់អនុគណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាល និងអនុគណៈកម្មការរដ្ឋបាលនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

គណៈកម្មការគ្រប់គ្រងគម្រោងលើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យត្រូវមានអនុគណៈកម្មការគ្រប់គ្រងគម្រោងលើការបណ្តុះបណ្តាល និងអនុគណៈកម្មការរដ្ឋបាល

និងហិរញ្ញវត្ថុដែលមានសមាសភាព តួនាទីភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

**ក. អនុគណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាល**

| | | | | | |
|---|---|---|---|---|---|
| ១. | ឯ.ឧ.បណ្ឌិត | **សៀង** | **សុវណ្ណា** | នាយកវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២. | លោកបណ្ឌិត | **ហេង** | **គ្រេង** | ប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | អនុប្រធាន |
| ៣. | លោកបណ្ឌិត | **នួន** | **ទីរ៉ា** | នាយករងវិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៤. | លោកបណ្ឌិត | **ច័ន្ទ** | **រ័ត្ន** | ប្រធានមជ្ឈ.ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី | ស.អចិន្ត្រៃយ៍ |
| ៥. | លោក | **ម៉ៅ** | **សារឿន** | ប្រធានដេប៉ាតឺម៉ង់អប់រំ នៃវិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦. | លោកបណ្ឌិត | **ស៊ុន** | **សុម៉ារ៉ា** | អ្នកសម្របសម្រួលកម្មវិធីបណ្តុះបណ្តាល | សមាជិក |
| ៧. | លោក | **ស្តាន់** | **នីស្លាស** | អ្នកប្រឹក្សាគរុកោសល្យ | សមាជិក |
| ៨. | លោក | **គង់** | **ម៉ាណែត** | គ្រូឧទ្ទេស | សមាជិក |
| ៩. | លោក | **ជី** | **គីមអ៊ី** | គ្រូឧទ្ទេស | សមាជិក |
| ១០. | លោក | **ស្រ៊ូ** | **លីហ៊ុល** | គ្រូឧទ្ទេស | សមាជិក |
| ១១. | លោក | **គេ** | **សៅរិទ្ធ** | គ្រូឧទ្ទេស | សមាជិក |

អនុគណៈកម្មការនេះមានតួនាទីភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- ជាជំនួយការឱ្យគណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ
- រៀបចំលក្ខខណ្ឌលម្អិតសម្រាប់ជ្រើសរើសនិស្សិតឱ្យចូលរៀន និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន
- សហការជាមួយអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលឱ្យស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ ការអភិវឌ្ឍរបស់ប្រទេស និងពិភពលោក ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់គ្រងការសិក្សា ការបង្រៀន ការប្រឡង ការវាយតម្លៃនិក្ខេបបទ និងការប្រគល់សញ្ញាបត្រ រៀបចំបញ្ជីឈ្មោះនិស្សិតបញ្ចប់ការសិក្សាជាស្ថាពរ ដើម្បីសុំការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា
- ធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា និងការបណ្តុះបណ្តាលប្រចាំឆមាស ជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា។

**ខ. អនុគណៈកម្មការរដ្ឋបាល និងហិរញ្ញវត្ថុ**

| | | | | | |
|---|---|---|---|---|---|
| ១. | ឯកឧត្តម | **ខួន** | **មាស** | អគ្គនាយក នៃអគ្គ. រដ្ឋបាល និងហិរញ្ញវត្ថុ | ប្រធាន |
| ២. | ឯកឧត្តម | **ទេព** | **តិយ្យោរិទ្ធ** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | លោក | **មូ** | **សម្បត្តិ** | នាយកហិរញ្ញវត្ថុ នៃអង្គការខេប | អនុប្រធាន |
| ៤. | លោក | **បាន** | **គនហេង** | អនុប្រ.ការិ.គណនេយ្យនៃវិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. | លោក | **ឈួន** | **សារ៉ាន់** | នា.រដ្ឋបាលនិងធនធានមនុស្ស នៃអង្គការខេប | សមាជិក |
| ៦. | លោក | **ស៊ីម** | **សូរិយា** | បុគ្គលិកផ្នែកហិរញ្ញវត្ថុ នៃអង្គការខេប | សមាជិក |

អនុគណៈកម្មការនេះមានតួនាទីភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- ជាជំនួយការឱ្យគណៈកម្មការគ្រប់គ្រងគម្រោងលើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ
- រៀបចំ និងសម្របសម្រួលកិច្ចប្រជុំតាមគ្រា និងតាមការចាំបាច់ ដើម្បីពិគ្រោះយោបល់ ពិភាក្សាសម្របសម្រួលបូកសរុប ឬសម្រេច លើសំណើគម្រោងថវិកា
- ធ្វើផែនការសកម្មភាពព្រមទាំងវឌ្ឍភាព តាមដានការពិនិត្យ និងវាយតម្លៃសមិទ្ធផល
- ដំណោះស្រាយបញ្ហាប្រឈម ដែលទាក់ទងនឹងការរៀបចំការបណ្តុះបណ្តាល ព្រមទាំងការដឹកនាំ ការគ្រប់គ្រង និងសម្របសម្រួលនានា
- រៀបចំផែនការថវិកាបង្កើតស្នើនិងអនុវត្តផែនការប្រតិបត្តិគម្រោងថវិកានិងផែនការសកម្មភាពសម្រាប់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំឯកទេសប្រឹក្សាគរុកោសល្យ
- ធ្វើរបាយការណ៍រាល់សកម្មភាពប្រចាំឆមាស ជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៤.-**

ការបំពេញភារកិច្ចរបស់អនុគណៈកម្មការគ្រប់គ្រងគម្រោងលើការបណ្តុះបណ្តាល និងអនុគណៈកម្មការរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុង និងលិខិតបទដ្ឋាននានារបស់វិទ្យាស្ថានជាតិអប់រំដែលមានស្រាប់។ ទីកន្លែងអនុវត្តការបណ្តុះបណ្តាលនេះស្ថិតក្នុងអាគារ I នៃវិទ្យាស្ថានជាតិអប់រំ ដោយប្រើប្រាស់ថវិកាពីក្រសួងអប់រំ យុវជន និងកីឡា និងពីដៃគូអភិវឌ្ឍន៍ ក្នុងការបំពេញការងាររបស់ខ្លួន ដោយមានការទទួលខុសត្រូវចំពោះមុខក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការអគ្គនាយកនៃអគ្គនាយកដ្ឋានយុវជនអគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៩

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង អ.យ.ក
- ដូចប្រការ៦
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ នា.នីតិកម្ម